ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ :.........៧៤១...........ក.ប /ស.ជ.អ

**សេចក្តីជូនដំណឹង**
**ស្តីពី**
**ការជ្រើសរើសមន្ត្រីរាជការ និងសិស្ស-និស្សិតឱ្យចូលបម្រើការងារ**
**ក្នុងក្របខ័ណ្ឌរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់ឆ្នាំ២០១៦**

**យោង** ៖ លិខិតលេខ ៤៨៧ មស.ក្រ.ខ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៦ របស់ក្រសួងមុខងារសាធារណៈ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់ សិស្ស-និស្សិត មន្ត្រីរាជការ (ក្របខ័ណ្ឌប្រភេទ ខ និង គ) បុគ្គលិកអង្គការ ក្រុមហ៊ុន ឱ្យបានជ្រាបថា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងឆ្នាំ២០១៦ នេះ ត្រូវការជ្រើសរើសមន្ត្រីរាជការក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ (ក្របខ័ណ្ឌប្រភេទ "ក") ចំនួន **១០៥** កន្លែងដោយបែងចែកទៅតាមអង្គភាពដូចខាងក្រោម ៖

| ល.រ | អង្គភាពជ្រើសរើស | ក្របខ័ណ្ឌ | ចំនួន | ល.រ | អង្គភាពជ្រើសរើស | ក្របខ័ណ្ឌ | ចំនួន |
|---|---|---|---|---|---|---|---|
| ១ | ទីស្តីការក្រសួង | ក | ៤៣ | ១៤ | មន្ទីរ ក.ប ខេត្តក្រចេះ | ក | ២ |
| ២ | មន្ទីរ ក.ប រាជធានីភ្នំពេញ | ក | ២ | ១៥ | មន្ទីរ ក.ប ខេត្តមណ្ឌលគិរី | ក | ៣ |
| ៣ | មន្ទីរ ក.ប ខេត្តស្វាយរៀង | ក | ២ | ១៦ | មន្ទីរ ក.ប ខេត្តរតនគិរី | ក | ៣ |
| ៤ | មន្ទីរ ក.ប ខេត្តព្រះសីហនុ | ក | ២ | ១៧ | មន្ទីរ ក.ប ខេត្តស្ទឹងត្រែង | ក | ២ |
| ៥ | មន្ទីរ ក.ប ខេត្តសៀមរាប | ក | ៣ | ១៨ | មន្ទីរ ក.ប ខេត្តព្រះវិហារ | ក | ៤ |
| ៦ | មន្ទីរ ក.ប ខេត្តកំពង់ស្ពឺ | ក | ២ | ១៩ | មន្ទីរ ក.ប ខេត្តពោធិ៍សាត់ | ក | ២ |
| ៧ | មន្ទីរ ក.ប ខេត្តកំពង់ឆ្នាំង | ក | ៤ | ២០ | មន្ទីរ ក.ប ខេត្តបាត់ដំបង | ក | ៣ |
| ៨ | មន្ទីរ ក.ប ខេត្តកំពង់ចាម | ក | ៤ | ២១ | មន្ទីរ ក.ប ខេត្តបន្ទាយមានជ័យ | ក | ២ |
| ៩ | មន្ទីរ ក.ប ខេត្តត្បូងឃ្មុំ | ក | ៤ | ២២ | មន្ទីរ ក.ប ខេត្តឧត្តរមានជ័យ | ក | ៣ |
| ១០ | មន្ទីរ ក.ប ខេត្តកណ្តាល | ក | ១ | ២៣ | មន្ទីរ ក.ប ខេត្តកែប | ក | ២ |
| ១១ | មន្ទីរ ក.ប ខេត្តតាកែវ | ក | ១ | ២៤ | មន្ទីរ ក.ប ខេត្តកោះកុង | ក | ៣ |
| ១២ | មន្ទីរ ក.ប ខេត្តព្រៃវែង | ក | ២ | ២៥ | មន្ទីរ ក.ប ខេត្តប៉ៃលិន | ក | ២ |
| ១៣ | មន្ទីរ ក.ប ខេត្តកំពង់ធំ | ក | ២ | ២៦ | មន្ទីរ ក.ប ខេត្តកំពត | ក | ២ |
| **សរុប ១០៥ (កន្លែង)** | | | | | | | |

❖ **ចំពោះបេក្ខជន ដែលមានបំណងចង់ទៅបម្រើការងារនៅតាមបណ្តាមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី ខេត្ត ក្រោមឱវាទក្រសួង អាចដាក់ពាក្យនៅទីស្តីការក្រសួងបាន លុះត្រាតែបេក្ខជននោះមានទីកន្លែងកំណើត ឬ អាសយដ្ឋានរស់នៅបច្ចុប្បន្ននៅក្នុងរាជធានី ខេត្តនោះ។**

## ១-កម្រិតសញ្ញាបត្រ និងលក្ខខណ្ឌនៃការជ្រើសរើស

- បេក្ខជនត្រូវមានសញ្ជាតិខ្មែរ
- បេក្ខជនត្រូវមានអាយុច្រើនបំផុត ៣០ឆ្នាំ សម្រាប់សិស្ស-និសិត្ស និង ៤៥ឆ្នាំសម្រាប់មន្ត្រីរាជការ
- បេក្ខជនជាមន្ត្រីរាជការត្រូវមានអតីតភាពការងារយ៉ាងតិច ៣ឆ្នាំ និងមានលិខិតអនុញ្ញាតឱ្យប្រឡងពីប្រធានអង្គភាព និងត្រូវអនុញ្ញាតឱ្យផ្ទេរក្របខ័ណ្ឌ ឬផ្លាស់កន្លែងធ្វើការនៅពេលប្រឡងជាប់ជាស្ថាពរ
- បេក្ខជនជាមន្ត្រីរាជការនឹងត្រូវបានរក្សាអតីតភាពការងារ ប៉ុន្តែតួនាទី ឬមុខតំណែងមិនត្រូវបានរក្សាទេ
- សញ្ញាបត្រយ៉ាងទាបបរិញ្ញាបត្រឬសញ្ញាបត្រសមមូល
- ផ្តល់អាទិភាពដោយបន្ថែមពិន្ទុលើមធ្យមភាគចុងក្រោយ នៃពិន្ទុសរុប ១០០% ចំពោះ ៖
  - ១/ បេក្ខជនជាស្ត្រី និងជនជាតិដើមភាគតិច ត្រូវបានលើកទឹកចិត្តនិងផ្តល់អាទិភាព
  - ២/ ក្រសួងនិងទទួលយកជនពិការ ០១ រូប (ដែលអាចបម្រើការងារបាន) ដោយស្វ័យប្រវត្តិក្នុងចំណោមបេក្ខជនជាជនពិការដែលបានដាក់ពាក្យប្រឡងហើយទទួលបានពិន្ទុខ្ពស់ជាងគេ
  - ៣/ បេក្ខជនជាមន្ត្រីជាប់កិច្ចសន្យា ............................................................ បន្ថែម ១០ ពិន្ទុ

ការបន្ថែមនេះ ផ្តល់ជូនតែមួយប្រភេទក្នុងករណីដែលបេក្ខជនមានលក្ខណៈសម្បត្តិលើសពី១ ដោយលក្ខខណ្ឌបន្ថែមពិន្ទុច្រើនជាងក្នុងចំណោមលក្ខខណ្ឌដែលបេក្ខជនមាន។

## ២-វិញ្ញាសា និងថេរវេលាប្រឡង

- ចំណេះដឹងទូទៅពាក់ព័ន្ធ រដ្ឋបាល និងវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ........................................................................................................................ រយៈពេល ២ម៉០០នាទី (មេគុណ៣)
- ភាសាអង់គ្លេស (QCM) ........................................................ រយៈពេល ១ម៉៣០នាទី (មេគុណ១)

❖ **<u>វិញ្ញាសាផ្ទាល់មាត់៖</u> ក្រសួងនឹងជូនដំណឹងនាពេលក្រោយសម្រាប់បេក្ខជនដែលបានប្រឡងជាប់វិញ្ញាសាសរសេរ ។**

**<u>បញ្ជាក់៖</u>** បេក្ខជនទាំងពីរភេទ ត្រូវអនុវត្តតាមការកំណត់វិញ្ញាសាប្រឡងខាងលើ ដោយមិនអាចតវ៉ានៅពេលប្រឡង ដើម្បីឱ្យមានការកែសម្រួលតាមជំនាញរបស់ខ្លួនឡើយ ។

## ៣-កាលបរិច្ឆេទផ្តល់ពាក្យ-ទទួលពាក្យ និងឈប់ទទួលពាក្យ

- កាលបរិច្ឆេទផ្តល់ពាក្យ និងទទួលពាក្យចាប់ពីថ្ងៃជូនដំណឹងនេះតទៅរៀងរាល់ម៉ោងធ្វើការ ពេលព្រឹកចាប់ពីម៉ោង ០៧:៣០-១១:៣០នាទី និងពេលរសៀលចាប់ពីម៉ោង ១៤:៣០-១៧:០០នាទី ។
- កាលបរិច្ឆេទឈប់ទទួលពាក្យ នៅថ្ងៃទី**២៩ ខែកញ្ញា ឆ្នាំ២០១៦ វេលាម៉ោង ៥:០០ នាទីល្ងាច**

**<u>បញ្ជាក់</u> ៖** ពេលមកដាក់ពាក្យសុំប្រឡង បេក្ខជនទាំងពីរភេទត្រូវនាំមកជាមួយ នូវសញ្ញាបត្រច្បាប់ដើមដើម្បីបង្ហាញដល់មន្ត្រីទទួលខុសត្រូវ។

## ៤-កាលបរិច្ឆេទប្រឡង និងមណ្ឌលប្រឡង

- មណ្ឌលប្រឡងនឹងបិទផ្សាយនៅទីស្តីការក្រសួង **នាថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៦**
- កាលបរិច្ឆេទប្រឡង**ថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៦**

## ៥-សំណុំលិខិតចុះឈ្មោះប្រឡង

- ពាក្យសុំចុះឈ្មោះប្រឡង ............................................................ ចំនួន ០១ ច្បាប់
- សេចក្តីចម្លងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ និងបរិញ្ញាបត្រ ឬសញ្ញាបត្រដែលមានតម្លៃស្មើដោយមានបញ្ជាក់ពីអាជ្ញាធរដែនដី ........................................ ចំនួន ០១ ច្បាប់
- ជីវប្រវត្តិរូបសង្ខេបមានបិទរូបថត ៤x៦ ............................................ ចំនួន ០១ ច្បាប់
- សលាកបត្រឯកត្តជន ............................................................ ចំនួន ០១ ច្បាប់
- កិច្ចសន្យាបម្រើការងារក្រសួង ................................................ ចំនួន ០១ ច្បាប់

- បង្កាន់ដៃបង់សិទ្ធិប្រឡង ........................................................................ ចំនួន ០១ ច្បាប់
- រូបថតថ្មី ៤x៦ ថតចំពីមុខគ្មានពាក់វ៉ែនតា ឬមួក .............................................. ចំនួន ០២ សន្លឹក
- លិខិតថ្កោលទោស (ក្រោយពេលប្រឡងជាប់ជាស្ថាពរ) ........................................ ចំនួន ០២ ច្បាប់
- លិខិតពិនិត្យកាយសម្បទា (ក្រោយពេលប្រឡងជាប់ជាស្ថាពរ) ............................. ចំនួន ០២ ច្បាប់
- ប្រកាសស្តីពីការប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យាសម្រាប់ឆ្នាំ២០១៦ សម្រាប់បេក្ខជន ជាមន្ត្រីជាប់កិច្ចសន្យា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ......................... ចំនួន ០១ ច្បាប់

**៦-កំណត់សំគាល់**

- បេក្ខជនត្រូវសរសេរបំពេញពាក្យសុំប្រឡងដោយដៃ ចុះហត្ថលេខា ឬផ្តិតស្នាមមេដៃ និងមកដាក់ពាក្យដោយផ្ទាល់ ព្រមទាំងភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធ ដូចមានចែងក្នុងចំណុច "៥"។
- កន្លែងទំនាក់ទំនងផ្តល់ពាក្យ និងទទួលពាក្យប្រឡង ៖
  - ក. សម្រាប់ទីស្តីការក្រសួង នាយកដ្ឋានរដ្ឋបាល និងបុគ្គលិក ***អាសយដ្ឋានអគារលេខ ៣ មហាវិថី សហព័ន្ធរុស្សី សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក (ទូរស័ព្ទ ០២៣ ៨៨៤ ៣៧៥)*** ជិតវិទ្យាស្ថានភាសាបរទេសនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។
  - ខ. គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត ដែលត្រូវជ្រើសរើស។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសិស្ស-និស្សិត មន្ត្រីរាជការ (ក្របខ័ណ្ឌប្រភេទ ខ និង គ) បុគ្គលិក អង្គការ ក្រុមហ៊ុន ដែលមានបំណងចង់ដាក់ពាក្យសុំប្រឡងមេត្តាជ្រាប និងអនុវត្តតាមការគួរ៕

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**ចម្លងជូន៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- អង្គភាពប្រឆាំងអំពើពុករលួយ "ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់អង្គភាពចំណុះក្រសួង "ដើម្បីជួយផ្សព្វផ្សាយ"
- ឯកសារ-កាលប្បវត្តិ